ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

លេខ ៨

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណឺម៉ង់

គ្រិ. ឆ្នាំ ១៩២៧

ព. ស. ២៤៧០

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ទំព័រ

១- ព្រះរាជកំណត់ពិធីបុណ្យរាជាភិសេក ព្រះករុណា ព្រះបាទសម្តេច ព្រះ ស៊ីសុវត្ថិ មុនីវង្ស ព្រះចៅក្រុងកម្ពុជាធិបតី . . . . . . ៤០៧

២- តាំងតុសៀវភៅរបស់ព្រះរាជបណ្ណាល័យកម្ពុជាក្នុងឱកាសបុណ្យ រាជាភិសេក ព្រះករុណាព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស . . . ៤៣៨

៣- អំពីព្រះបាទសម្តេចព្រះ ស៊ីសុវាងវង្ស ព្រះចៅក្រុងលាវ ស្តេចចូលក្រសាលក្នុង ព្រះរាជបណ្ណាល័យកម្ពុជា . . . . . ៤៤០

៤- សេចក្តីអធិប្បាយ ពីព្រះរាជបណ្ណាល័យ របស់លោកស៊ីលវ៉ាំងឡេវី ជាងហ្វាងចាស់សាលាបារាំង ជប៉ុន នៅក្រុងតូក្យូស្រង់មកពីទស្សនាវដ្តី យី ប៉ុន ឈ្មោះ យ៉ុង អាំស . . . . . . . ៤៤២

# ព្រះរាជពិធីបុណ្យរាជាភិសេក

## ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស

ចមចក្រពង្សហរិរាជ បរមិន្ទរ ភូវណៃក្រៃកែវហ្វាសុឡាឡៃ ព្រះចៅក្រុងកម្ពុជាធិបតី

*ជាអម្ចាស់ជីវិតលើត្បូង*

---

## ក្រុងកម្ពុជាធិបតី

### ព្រះរាជកំណត់បុណ្យរាជាភិសេក

ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស ចមចក្រពង្ស ហរិរាជ បរមិន្ទរ ភូវណៃក្រៃកែវហ្វា សុឡាឡៃ ព្រះចៅក្រុងកម្ពុជាធិបតី ជាអម្ចាស់ជីវិតលើត្បូង ។

ព្រះអង្គជាព្រះរាជបុត្រាច្បង នៃព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិបតីនិងសម្តេចព្រះវររាជជននី បរមបពិត្រ ព្រះនាម វ៉ណ្ណ ទ្រង់ប្រសូតនៅក្រុងភ្នំពេញ ក្រុងកម្ពុជាធិបតី នៅថ្ងៃចន្ទ ១០កើតខែបុស្ស ឆ្នាំជូតអដ្ឋស័កព្រះពុទ្ធសករាជ ២៤២០ មហាសករាជ ១៦៣៨ ត្រូវគ្នានឹងថ្ងៃ ខែ យ៉ាំងវីយេរ ឆ្នាំបារាំង ១៨៧៦ ។

ទ្រង់បានរៀនវិជ្ជាយុទ្ធនាសង្គ្រាម ក្នុងក្រុងបារាំងសែស ហើយបានតាំងជាទីសែហ្វជីបាតៃយ៉ុង កុំម៉ង់ដង្គ មេទ័ពស័ក្តិ ៤ ក្នុងក្រុមព្យូហៈបារាំងសែស ហើយបានរង្វាន់ការមានគុណបំណាច់ មហាប្រសើរ

បានសុវណ្ណបត្រ ជាសម្ដេចព្រះកែវហ្វា រួចទ្រង់ទទួលរាជសម្បត្តិ តពីព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ជាព្រះវររាជបិតា តាំងពីថ្ងៃអង្គារ ១១ កើត ខែស្រាពណ៍ ឆ្នាំថោះ នព្វស័ក ព្រះពុទ្ធសករាជ ២៤៧០ ត្រូវគ្នានឹងថ្ងៃ ៩ ខែ អ៊ូត ឆ្នាំ ១៩២៧ ក្នុងព្រះជន្មវស្សា ៥៦ ឆ្នាំ ។

## ព្រះរាជពិធីរាជាភិសេក

ចូលបុណ្យ តាំងពីថ្ងៃ សុក្រ ៣ កើត ខែទុតិយាសាឍ ឆ្នាំរោង សំរិទ្ធិស័ក ព្រះពុទ្ធសករាជ ២៤៧១ រៀងដល់ថ្ងៃពុធ ៩ កើត ខែឆ្នាំជាមួយគ្នា គឺពីថ្ងៃ ២០ សូយេតទៅដល់ ២៥ ខែជាមួយគ្នា ឆ្នាំបារាំង ១៩២៨ ។

តាំងព្រះរាជមណ្ឌលធម្ម ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមានទីគ្រែពិធីជាទីតម្កល់ព្រះពុទ្ធរូប ព្រះទេវរូប និងគ្រឿងបញ្ចកកុធភណ្ឌ និងទីប្រជុំបុណ្យធំ ខាងមុខព្រះមហាស្វេតច្ឆត្រព្រះបល្ល័ង្ក ។ មានកនទេវតា ៣ ថ្នាក់ ៨ ទិសជុំវិញ ព្រះទីនាំងទេវាវិនិច្ឆ័យ និងកនទេវតាធំ ៧ ថ្នាក់ ១ ទៀត តាំងខាងមុខ ព្រះទីនាំងទេវាវិនិច្ឆ័យ តាំងបល្ល័ង្ក ៩ ជាន់ មានព្រះមហាបុស្សកមាស សម្រាប់ថ្វាយទឹកស្រង់ខាងទិសបូព៌ានៃព្រះទីនាំងទេវាវិនិច្ឆ័យ ។ សង់រោងមណ្ឌល ៤ ទិសជុំវិញ តាមព្រះទ្វារក្រៅកំផែង ព្រះបរមរាជវាំង រោងមណ្ឌលមួយៗ ធំ ៤ ម៉ែត្រ ជ្រុងស្មើ លើកទក្រាលក្ដារ មានរបៀងនិងព្រះរាជវតិជុំវិញ មានកនទេវតា ៣ ថ្នាក់ ១ និងដងគោមលាបថ្នាំ ១ មានគោម ១ អុជគ្រប់រោងមណ្ឌល ។

ព្រះសង្ឃនាយកតាំងពីគណៈ និងសេនាបតីនាម៉ឺនសព្វមុខមន្ត្រី ទៅក្រម ក្នុងក្រុងនិងក្នុងខែត្រនៃព្រះនគរ តាំងគ្រឿង សក្ការបូជា គោរពទៅតាក់ថែវ ក្នុងកំផែងសីមាព្រះបរមរាជវាំង ។

ត្រូវក្រមការបណ្ឌិតតច្ចអមេ្យាះសីមា គប់ព្រះទីនាំងព្រះដំណាក់ទាំងអស់ មកប្រជុំទីនៃត្រពិធីសូត្រមន្ត ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ។

១- ព្រះពេងមណ្ឌលធំ គឺព្រះទីនាំងទេវាវិនិច្ឆ័យត្រូវស្តេចព្រះឥស្សរកធិបតី ១, ព្រះព្រហ្មាធិរាជ ១, ព្រះម៉ង្គលរ ១, ព្រះជ័យាធិបតី ១, ព្រះធម្មរាជ ១, ព្រះបរមចារ ១, ព្រះទេពចារ ១ ព្រះឥន្ទកោសាវង្សា ១, ជា ៨ នាក់ កាន់ព្រាតតាំងព្រះរាជពិធីចម្រើនព្រះសិទ្ធសេក្តសស័ន្ត ។

២- ពេងមណ្ឌលទិសបូព៌ា ត្រូវព្រះអរិយសាល ១, និងបារគូ ៣ នាក់ កាន់ព្រាតតាំងព្រះរាជពិធីចម្រើនសិទ្ធសេក្តសស័ន្ត ។

៣- ពេងមណ្ឌលទិសទក្សិណ ត្រូវព្រះធម្មរិន្ទ ១ និងបារគូ ៣ នាក់ កាន់ព្រាតតាំងចម្រើនព្រះសិទ្ធសេក្តសស័ន្ត ។

៤- ពេងមណ្ឌលទិសបស្ចិម ត្រូវព្រះធម្មចារ ១ និងបារគូ ៣ នាក់ កាន់ព្រាតតាំងចម្រើនព្រះសិទ្ធសេក្តសស័ន្ត ។

៥- ពេងមណ្ឌលទិសឧត្តរ ត្រូវព្រះឥន្ទសរជ័យ និងបារគូ ៣ នាក់ កាន់ព្រាតតាំងព្រះរាជពិធីចម្រើនព្រះសិទ្ធសេក្តសស័ន្ត ។

## គម្រប់ ១ ថ្ងៃសុក្រ ៣ កើតខែទុតិយាសាធគឺថ្ងៃ ២០ សូយេត

វេលាម៉ោង ១៦ គឺម៉ោង ៤ រសៀល រៀបពិធីឡើងព្រះទីនាំងព្រះមហាមន្ទីរជាទីប្រថាប់ និង ក្រឡាព្រះបន្ទំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាប់នឹងព្រះទីនាំងទេវាវិនិច្ឆ័យ មានព្រះរាជបល្ល័ង្កស្វេតច្ឆត្រខាងក្នុង សម្រាប់ទទួលក្រុមស្រ្តី ត្រង់ព្រះមហាមន្ទីរ មានព្រះទីនាំងចក្រពត្រជាទីក្រឡាព្រះបន្ទំព្រះករុណានៅឯខាងត្បូង និងព្រះទីនាំងនារីរ័ត្នសោភាជាទីក្រឡាបន្ទំសម្រាប់ព្រះមហេសី ឬព្រះស្នំ និងហោត្រៀងជាទីស្វាយ ឬទុកគ្រឿងទ្រង់នៅខាងលិច ។

ព្រះករុណាទ្រង់ព្រះពស្ត្រពណ៌ខៀវតាមពណ៌ថ្ងៃសុក្រ ស្តេចយាងព្រាំបាទលើមាគ៌ាក្រាលសំពត់ស លើកទ្រូលតាមក្បួនហែ ពីព្រះដំណាក់ច័ន្ទ ចូលទៅឡើងព្រះទីនាំងព្រះមហាមន្ទីរតាមទំនៀម ។ ឧកញ៉ាវាំងវរវៀងជ័យ ត្រូវចាំទទួលព្រះករុណាក្នុងព្រះទីនាំងព្រះមហាមន្ទីរ ។

ទីស្តេចក្សត្រីនិងព្រះស្នំក្រុមការនិងជំទាវខុនណាងក្រាបបង្គំគាល់ក្នុងព្រះទីនាំងមហាមន្ទីរ និងក្នុងព្រះទីនាំងនារីរ័ត្នចក្រពត្រសោភា ។

ទីស្តេចក្សត្រានិងអគ្គមហាសេនាសេនាបតីនាម៉ឺនសព្វមុខមន្ត្រី ក្រាបបង្គំគាល់ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមុខព្រះមហាបល្ល័ង្កស្វេតច្ឆត្រ ។

ម៉ោង ១៧ និង ៣០ នាទី គឺម៉ោង ៥ កន្លះល្ងាច ព្រះករុណាថ្វាយបង្គំថ្វាយព្រះបិដរក្នុងហោអដ្ឋិ ។

ម៉ោង១៨គឺម៉ោង ៦ ល្ងាច ឧកញ៉ាហោរាធិបតីបាន ហ្វាន់សូត្រប្រកាស

ទេវតា ចូលបុណ្យរាជាភិសេកនៅកនទេវតាធំខាងមុខព្រះទីនាំងទេពវិនិច្ឆ័យ ។

ម៉ោង ១៨ និង ៣០ នាទី គឺម៉ោង ៦ កន្លះល្ងាច អុជពន្លឺប្រទីបគ្រឿងសក្ការបូជា ក្នុងព្រះបរមរាជវាំង និងពន្លឺខាងក្នុង ខាងមុខព្រះទីនាំងទេពវិនិច្ឆ័យនិងគ្រឿងតាំងតុ ។

ព្រះករុណាទ្រង់ព្រះពស្ត្រពណ៌ខៀវ និងព្រះភូសាពណ៌ខៀវ ព្រមទាំងគ្រឿងព្រះរាជឥស្សរិយយស ស្ដេចយាងព្រះបាទតាមក្បួនហែ មានស្ត្រីកាន់ផ្កាមាស ៤ ផ្កាប្រាក់ ៤ ប្រណាម្យហែមុខ និងស្ត្រីអញ្ជើញគ្រឿង ១៦ នាក់ហែក្រោយ ។ ហែពីក្នុងព្រះទីនាំងព្រះមហាមន្ទីរបេញទ្វារព្រះដាយគ្រឿន មកគង់នៅព្រះទីនាំងទេពវិនិច្ឆ័យ មានសម្ដេចព្រះឥសីកន្ធិបតី អញ្ជើញព្រះនារាយណ៍ហែមុខ ។

ទ្រង់ប្រថាប់លើព្រះទីនាំងកៅអី អុជគ្រឿងពុទ្ធបូជាថ្វាយបង្គំព្រះរតនត្រៃ ហើយស្ដេចយាងទៅអុជទៀនជ័យ ជាមួយនិងព្រះសង្ឃនាយកក្នុងព្រះទីនាំងទេពវិនិច្ឆ័យ ហើយទ្រង់ថ្វាយត្រៃព្រះសង្ឃ ២៦ អង្គគ្រងរួចក្រុមសង្ឃការីខ្វង់គោរងអារាធនាសីលនិមន្តព្រះសង្ឃចម្រើនព្រះពុទ្ធមន្តពិធីឡើងព្រះទីនាំងមហាមន្ទីរ និងធ្វើព្រះសិទ្ធរសព្រះពុទ្ធមន្ត ទុកថ្វាយស្រង់ក្នុងបុណ្យរាជាភិសេក ។

ព្រះរាជវង្សានុវង្សគ្រប់អង្គនិងអគ្គមហាសេនាសេនាបតី នាម៉ឺនសព្វមុខមន្ត្រីចៅក្រមក្នុងក្រុង និងក្នុងខេត្តស្លៀកសំពត់ និងពាក់អាវសារបាប់ពណ៌

លើក ប្ត ជាមួងនិងគ្រឿងឥស្សរិយយស ជួបជុំក្រាបថ្វាយបង្គំគាល់តាមដំណែងក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះសង្ឃចម្រើនព្រះពុទ្ធមន្ត រួចព្រះករុណាស្ដេចយាងចូលតាមក្បួនហែចូលទៅប្រថាប់ក្នុងព្រះទីនាំងចក្រពត្រ ទ្រង់គ្រឿងពណ៌ស ទទួលសមាទានសីលក្នុងព្រះទីនាំងទ្រង់ធម៌ជាបរិសុទ្ធក្នុងព្រះអង្គ ។

ម៉ោង ២០ គឺម៉ោង ៨ យប់ លៀងភោជនាហារព្រះរាជវង្សានុវង្ស អគ្គមហាសេនា សេនាបតី នាម៉ឺនសព្វមុខមន្ត្រី និង ចៅក្រម ។

ពីម៉ោង ២១ ដល់ម៉ោង ២៤ គឺពីម៉ោង ៩ យប់ ទៅដល់អធ្រាត្រ រាំល្ខោនក្នុងរោងព្រះទីនាំងពិធីបុណ្យ និង ល្បែងមហោស្រពខាងមុខព្រះលាន អុជកាំជ្រួចរន្ទាភ្លើងទៀន ។

## គម្រប់ពីរ ថ្ងៃសៅរ៍ ៤ កើតខែទុតិយាសាឍ គឺថ្ងៃ ២១ ខែសូយេត

ម៉ោង៩ព្រឹក ព្រះករុណាទ្រង់ព្រះពស្ត្រនិងព្រះភូសាពណ៌ហានឡៅ ស្ដេចយាងតាមក្បួនហែដដែល ចេញនិមន្តព្រះសង្ឃដែលបានចម្រើនព្រះពុទ្ធមន្តពីល្ងាចសូត្រតាហ៊ុំថ្វាយ វេរព្រះភោជនាហារព្រះសង្ឃឆាន់ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមានតូរ្យតន្ត្រីមហោរីលេងថ្វាយ រួចទ្រង់ប្រគេនទេយ្យទាន ។

ព្រះរាជវង្សានុវង្ស អគ្គមហាសេនាសេនាបតីនាម៉ឺនសព្វមុខមន្ត្រី និង ចៅក្រមក្នុងក្រុង ក្នុងខែត្រស្លៀកពណ៌ដូចដែលនឹងគ្រឿងឥស្សរិយយស ជួបជុំក្រាបថ្វាយបង្គំគាល់ ។

លេងល្បែងមហោស្រពខាងមុខព្រះបរមរាជវាំងដល់ម៉ោង ១០ ព្រឹក ។

ព្រះករុណាព្រះរាជទានគ្រឿងឥស្សរិយយស និងរបស់ទុកព្រះកេរ្តិ៍ ខ្ញុំរាជការខ្មែរ ។

ពីម៉ោង ១៥ ដល់ម៉ោង ១៨ គឺពីម៉ោង ៣ រសៀល ដល់ម៉ោង ៦ ល្ងាច រាំល្ខោនក្នុងព្រះទីនាំងពិធីបុណ្យ និងល្បែងមហោស្រព មុខព្រះលាន ។

ពីម៉ោង ១៨ ដល់ម៉ោង ២៤ គឺពីម៉ោង ៦ ល្ងាចដល់អធ្រាត្រ របៀបបុណ្យដូចថ្ងៃដំបូង ។

– គម្រប់ ៣ ថ្ងៃអាទិត្យ ៥ កើត ខែទុតិយាសាឍ គឺ ថ្ងៃ ២២ ខែ ស៊ូយេត :

របៀបបុណ្យដូចថ្ងៃគម្រប់ពីរ ។

ព្រះករុណាទ្រង់ពណ៌ក្រហម ។

– គម្រប់ ៤ ថ្ងៃច័ន្ទ ៦ កើតខែទុតិយាសាឍ គឺថ្ងៃ ២៣ ខែស៊ូយេត

ពីម៉ោង ៧ និង ៥ នាទីព្រឹក ជាមួយមហាវិជ័យមង្គល~~ឫក្ស~~ ព្រះករុណាទ្រង់គ្រឿងពណ៌ស ព្រះភូសាជាយស ស្តេចយាងតាមក្បួនហែដូចដែល មកក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ បារគូផ្លុំស័ង្ខក្រលែងពីងពាំង និងប្រគុំតូរ្យតន្ត្រីថ្វាយតាមទំនៀម ព្រះករុណាថ្វាយបង្គំព្រះពុទ្ធរូប ព្រះទេវរូប និមន្តព្រះសង្ឃដែលសូត្រព្រះពុទ្ធមន្តពីល្ងាច សូត្រជយន្តោថ្វាយជ័យស្រន់ ហើយព្រះករុណាទទួលលោកឡឺគូវ៉ែរណើរយេណេរ៉ាល់ ដឺឡាំងដូស៊ីន និងលោក ឡឺរ៉េស៊ីដង់ សុប៉េរីយើរ ឡារ៉េពូព្លិក បារាំងសែស ក្នុងក្រុងកម្ពុជា ជាមួយ នឹង សម្តេចព្រះសង្ឃនាយកពីរគណ: និង អគ្គមហាសេនា

សេនាបតី និងសម្តេចព្រះឥសីកន្ទធិបតី ហៃស្តេចយាងឡើងលើព្រះបល្ល័ង្ក ក្រោមព្រះមហាបុស្បក តាំងខាងមុខព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះករុណា គង់លើផែនសុវណ្ណផដើរបេនា និងជាតិហិង្គុលជាគាពកផសីហ៍ ក្រាលលើ ស្លឹកឧទុម្ពរព្រឹក្ស សម្តេចព្រះឥសីកន្ទធិបតី ថ្វាយស័ន្ធជ័យព្រឹក្ស ព្រះករុណាទ្រង់ទទួលកាន់ព្រះហស្តស្តាំ ជាព្រះតេជបេស្តា ព្រះករុណាឈម ព្រះភក្ត្រទៅបូព៌ាទិសា ។

ឧកញ៉ា ហោរាធិបតី ចាងហ្វាងក្រុមហោរា សូត្រប្រកាសអញ្ជើញ ទេវតា សូមចម្រើនសិរីសួស្តីជ័យមង្គល ថ្វាយព្រះករុណានៅទីគនទេវតា ហើយសង្ខណាកាំភ្លើង ២១ ណាត់ ។

ព្រះសង្ឃនាយក ទាំងពីរគណ: ថ្វាយព្រះឧទកធារាពុទ្ធមន្តស្រង់ សម្តេចព្រះឥសីកន្ទធិបតី ថ្វាយព្រះសិទ្ធរសក្ខស័ន្ធ ទ្រង់ស្រង់ហោង ព្រះកេសាតាមទំនៀម សម្តេចព្រះឥសីកន្ទធិបតីថ្វាយស្លឹកញ៉ៀសៀតព្រះ កាណ៌ធ្វេង ។

លោកឡូគ្គីវើរណើរយេរណេរ៉ាល់ និងលោកឡូរេស៊ីដង់សុប៉េរីយើរ និងអគ្គមហាសេនា សេនាធិបតី ក៏ជួយថ្វាយព្រះសិទ្ធរស ទ្រង់ស្រង់រួចហៃ ស្តេចយាងចុះមក ត្រូវព្រះពមាធិបតី ចាងហ្វាងក្រុមព្រះវង្សបុព្វជួស្រេប ព្រះបាទព្រះករុណា និងទឹកជូន ទឹកអប់លើជាសមាសជាសប្រាក់ រួចស្តេច យាងសណ្ឋិតលើផែន ផ្លាស់ព្រះពស្ត្រ ព្រះភូសា ហើយស្តេចយាងចូលទៅ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ តាមក្បួនហៃយាងទៅប្រថាប់ ក្នុងព្រះទីនាំង

បក្រពត្រវិញ ទ្រង់គ្រឿងព្រះពស្ត្រ ព្រះភូសាផាយត្អែកម្ពល តាមមហា
ក្សត្រពីបុរាណពេញព្រះរាជយស ។

ម៉ោង ៩ ព្រឹក ព្រះករុណាទ្រង់គ្រឿងសម្រាប់ព្រះមហាក្សត្រាធិរាជ តាមក្បួនហែធំដដែល ចេញមកក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ សម្ដេចព្រះឥសីភត្តធិបតីទទួលហែមុខទ្រង់ទទួលគំនាប់លោក ឡឺគូវែរណើរយេណេរ៉ាល់ដឺឡាំងដូស៊ីន និងលោក ឡឺរេស៊ីដង់ សុបេរីយើរ និង អស់លោកអ្នករាជការអ្នកជំនួញបារាំងសែស ដែលមកជួបជុំជួយបុណ្យ រួចទ្រង់ថ្វាយបង្គំព្រះពុទ្ធរូប ព្រះទេវរូប ទទួលសីលថ្វាយព្រះអង្គជាពុទ្ធុបដ្ឋាក ជាធម្មុប-ដ្ឋាក ជាសំឃុបដ្ឋាក ហើយវេរភោជនាហារ និង គ្រឿងទេយ្យទានដល់ព្រះភិក្ខុសង្ឃ ១ ថ្វាយព្រះពរនិមន្តទៅឆាន់ឯកុដិ ។

ព្រះករុណា ស្ដេចយាងទៅប្រថាប់លើព្រះទីនាំង កៅអីក្រាលសរបរិ-សុទ្ធឈមព្រះភក្ត្រទៅទិសបូព៌ា មានព្រះរាជគ្រូបារគ្គូបុរោហិតអង្គុយគាល់ជុំវិញតាំង ៨ ទិស មានបារគ្គូក្រៅលែងពីងតាំង ៨ នាក់ និងបារគ្គូជុំសង្ខ ទើប
/ សម្ដេចឥសីភត្តធិបតីថ្វាយព្រះឥសូរ ទ្រង់ឧបព្រះហស្តស្តាំ ថ្វាយព្រះនា-រាយណ៍ ទ្រង់ឧបព្រះហស្តឆ្វេង ហើយព្រះរាជគ្រូអង្គុយទិសបូព៌ា សូត្រថ្វាយព្រះគាថាតាមទិស រួចទ្រង់បង្វិលព្រះអង្គជាទក្ខិណា ដែលផ្ដោះព្រះភក្ត្រទៅទិសអាគ្នេយ៍ ទិសទក្សិណ ទិសនិរតី ទិសបច្ចិម ទិសពាយ័ព្យ ទិសឧត្តរ និងទិសឦសាន គ្រូវិឡបុរោហិតដែលអង្គុយប្រចាំទិស សូត្រថ្វាយព្រះគាថាតាមទិសគ្រប់ ១ ទិស តាមទំនៀមព្រាហ្មណ៍ រួចទ្រង់ព្រះ

កត្រៃទៅទិសបូព៌ាវិញព្រះរាជគ្រូប្រចាំទិសទាំង ៨ ថ្វាយសិរីសួស្តីមហាជ័យមង្គលព្រម ៗ គ្នា រួចសម្តេចព្រះឥសីកន្ទុំថ្វាយព្រះស័ង្ខរសព្រះរាជស័ង្ខទ្រង់ស្រោយ ។

៩ ឧកញ៉ាពិនិត្យវិនិច្ឆ័យចាងហ្វាងក្រុមព្រះអាលក្ខណ៍ សូត្រព្រះសុវណ្ណបត្តថ្វាយព្រះនាម ។

ឧកញ៉ាមហាមន្ត្រីក្រុមវៀនហ្វ៊ូ សូត្រថ្វាយព្រះមហាម្កុដរាជ្យ និងរាជសម្បត្តិសួយសារអាករ ព្រះនគរបាលក្រុងកម្ពុជាធិបតី និងព្រះរាជវង្សានុវង្សក្សត្រា និងអគ្គមហាសេនា សេនាបតី នាម៉ឺនសព្វមុខមន្ត្រី ខ្ញុំរាជការគ្រប់ដំណែង គ្រប់ទាំងខាងក្នុង ខាងក្រៅ និងស្រែចំការច្បារដំណាំ ទឹកដីព្រៃភ្នំក្នុងខុបខណ្ឌសីមា ព្រះមហានគរក្រុងកម្ពុជាធិបតី និងថ្វាយសព្វសាធុការពរ រួចព្រះរាជវង្សានុវង្សអគ្គមហាសេនា សេនាធិបតី នាម៉ឺនសព្វមុខមន្ត្រីខ្ញុំរាជការទាំងអស់ ដែលមកជួបជុំនៅទីនោះ មានទាន មានតុដាក់តម្កល់គ្រោសម្រាប់យសសក្តិ និងផ្កានិងទៀនទឹកអប់ តាមយសសក្តិក្រាបថ្វាយបង្គំម្តង ៗ ។

ព្រះករុណាទ្រង់មានព្រះរាជឱង្ការនូវព្រះបន្ទូល សូរសីហនាទ ព្រះរាជទានសព្វសាធុការពរហើយទ្រង់ព្រះរាជទានគ្រោសម្រាប់យសសក្តិមុខងារគ្រប់ដំណែង ឲ្យអស់រាជវង្សានុវង្សអគ្គមហាសេនាសេនាធិបតី នាម៉ឺនសព្វមុខមន្ត្រីទទួលធ្វើរាជការតាមដំណែង ធ្វើព្រះតេជគុណ និង ព្រះរាជទានស្រែចំការច្បារដំណាំ ទឹកដី ព្រៃភ្នំ ឲ្យអស់ខ្ញុំរាជការប្រជានុរាស្ត្រ

ទៅធ្វើបរកេស៊ីដោយសុខក្សេមក្សាន្តជាធម្មតាដូចដើមវិញ ។

ខ្ញុំរាជការទាំងអស់ទទួលក្រាបថ្វាយបង្គំម្តង ។

ព្រះករុណាគង់លើព្រះទីនាំងកៅអីមាស ។

លោក គូវែរណើរយេណេក៉ល់ និងលោក ឡឺរេស៊ីដង់សុប៉េរីយើរ ចូលថ្វាយគំនាប់ជួបជុំ ប្រជុំធំ នាំពតិមានថ្វាយសព្ទសាធុការពរ ពីគូវែរណើរម៉ង់ ដឺឡាពេព្វពិក បារាំងសែស ដែលទំនុកបម្រុងក្រុងកម្ពុជាធិបតី ហើយអញ្ជើញ និងហែស្តេចឡើងប្រថាប់លើព្រះបល្ល័ង្កវត្ន ក្រោមព្រះមហាស្វេត្រច័ត្រ ៩ ជាន់ សក្ខុណាកាំភ្លើង ២១ ណាត់ ហើយសម្តេចឥសីកខុធិបតី អញ្ជើញព្រះមហាម្កុដរាជ ជូនទៅលោកគូវែរណើរយេ-ណេក៉ល់ទ្រង់ថ្វាយព្រះករុណាតាំងព្រះនាមក្រុងបារាំងសែស ។

អញ្ជើញព្រះខ័នរាជ្យជូនទៅលោក ឡឺរេស៊ីដង់សុប៉េរីយើរ ថ្វាយទៅព្រះករុណាទ្រង់ទទួលកាន់ព្រះហស្តស្តាំ ហើយសេនាបតីនិងចៅក្រសួងថ្វាយហានព្រះគរ ព្រះសុពណ៌បាទ និងគ្រឿងសម្រាប់រាជតាមទំនៀម ។

ខ្ញុំរាជការក្រាបថ្វាយបង្គំម្តងទៀត ជាគម្រប់ ៣ ដងស្រេច ។

លោក គូវែរណើរយេណេក៉ល់ ថ្លែងអធិប្បាយ ថ្វាយសព្ទសាធុការពរ ។

ព្រះរាជគ្រូហែ ស្តេចយាងចុះមកគំនាប់លោកគូវែរណើរយេណេក៉ល់ និងលោក ឡឺរេស៊ីដង់ សុប៉េរីយើរ ហើយទ្រង់សូត្រព្រះរាជឧង្ការ គបព្រះតេជគុណក្រុងបារាំងសែសដែលជួយរក្សានគរ និងរាជការក្រុងកម្ពុជាធិបតី និងជួយជាអធិបតី ក្នុងការបុណ្យរាជាភិសេកព្រះអង្គ ។

លោក ឡឺគូវែរណឺរយេណេរ៉ាល់ និងលោក ឡឺរេស៊ីដង់សុប៉េរីយើរ និងមហាជនបារាំងសែស ដែលមកជួបជុំតាំងអស់ ចាប់ព្រះហស្តថ្វាយគំនាប់លាព្រះករុណាចេញទៅវិញ ។

ម៉ោង ១០ ព្រឹក ព្រះករុណា ស្តេចយាងតាមក្បួនហែចូលទៅវិញ ដល់ព្រះទីនាំង ទក្សិណប្រថាប់លើព្រះខែន ។ ទើបអ្នករាជានុពង្សក្រាបបង្គំទូលថ្វាយអស់ព្រះរាជវង្សានុវង្សក្សត្រិយ៍ និងព្រះស្នំក្រុមការព្រះស្រិង្គារ និងសព្ទសាធុការពរ ។

ភរិយាចាងហ្វាងក្រុមវៀនហ្វង ក្រាបបង្គំទូលថ្វាយជំទាវខុនណាង និងខ្ញុំរាជការក្សត្រីគ្រប់ក្រុម ហើយថ្វាយសព្ទសាធុការពរ ។

អស់ព្រះរាជវង្សានុវង្សក្សត្រី និងព្រះស្នំក្រុមការ ព្រះសិង្គារជំទាវខុនណាង និងខ្ញុំរាជការស្ត្រីគ្រប់ក្រុម មានផ្កា និងទៀនទឹកអប់ តម្កល់លើពានលើតុ តាមយសសក្តិ គ្រប់គ្នាក្រាបថ្វាយបង្គំម្តង ។

ព្រះករុណាទ្រង់មានព្រះរាជឱង្ការ ព្រះរាជទានពរសព្ទសាធុការវិញ អស់ខ្ញុំរាជការ ស្ត្រី ក្រាបថ្វាយបង្គំម្តង ។

ព្រះករុណាទ្រង់យាងចូលទៅក្នុងព្រះទីនាំងចក្រពត្រ អស់ខ្ញុំរាជការស្ត្រី ក្រាបថ្វាយបង្គំម្តងទៀត ជាគម្រប់ ៣ ដងស្រេច ។

ម៉ោង ១០ និង ៣០ នាទីព្រឹក ព្រះករុណាទ្រង់គ្រឿងពណ៌ដដែល ស្តេចព្រះរាជដំណើរយាងចេញតាមក្បួនហែមក ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ជួបជុំព្រះរាជវង្សានុវង្ស អគ្គមហាសេនាសេនាបតី នាម៉ឺនសព្វមុខមន្ត្រីថ្វាយ

ព្រះទក្ខិណាបន្ទិលព្រះពពិល ១៩ ជុំ ។

លែងមនុស្សទោសគ្រប់គុកក្នុងព្រះនគរ តាមព្រះរាជប្រកាសតាមសេចក្ដីសុំពីក្រសួង សេនាបតី ។

ម៉ោង ២០ គឺម៉ោង ៨ យប់ ព្រះករុណាទ្រង់ទទួលលៀងភោជនាហារ លោកឡឺ គូវែរណើរយេរេណាល់ និងលោកឡឺរេស៊ីដង់សុប៉េរីយ៉ើរ ។

ម៉ោង ៤២ គឺម៉ោង ១០ យប់ កំរោលានព្រះរាជទ្រព្យនិងកំសាន្តជុំក្នុងព្រះពន្លាប័ន្នធាយា ។

## គម្រប់ ៥ ថ្ងៃ អង្គារ ៧ កើតខែទុតិយាសាធគឺថ្ងៃ ២៨ សូរយេត

ម៉ោង ៧ ព្រឹក ព្រះករុណាទ្រង់គ្រឿងព្រះពស្ត្រព្រះភូសាពណ៌ស្វាយ ទ្រង់ព្រះម្កុដពេញព្រះរាជយស ស្ដេចយាងតាមក្បួនហែចេញពីព្រះទីនាំងទេវាវិនិច្ឆ័យ សន្ធូណាកាំភ្លើង ២១ ណាត់ ស្ដេចយាងឡើងគង់ព្រះរាជយានុមាត្យ ព្រមដោយក្បួនហែធំ និងព្រះរាជវង្សានុវង្ស ទ្រង់ព្រះពស្ត្រសារបាប់ព្រះភូសាផាយពណ៌ និងព្រះមាលាទ្រង់ព្រះពាត ឬព្រះភូសាសក្តិ ព្រះមាលាកាស អគ្គមហាសេនាយោង សេនាបតីគួយៀង ចេញប្រទក្សិណព្រះនគរទ្រង់ប្រោសប្រទានប្រាក់តាមមាគ៌ា តាំងពីមុខព្រះលានទៅទិសបូព៌ បត់តាមថ្នល់ទៅទក្សិណ ដល់ថ្នល់ទទឹងបត់ទៅទិស បស្ចិម ដល់ស្ពាននាគចូលព្រះពន្លាគក១ ។

លោក ឡឺរេស៊ីដង់ សុប៉េរីយ៉ើរ និង សម្ដេចឥសីកទូធិបតី ចាំទទួល

ព្រះករុណាស្តេចចូលប្រថាប់ ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យថ្វាយព្រះសិទ្ធសេក្រស់ស័ង្ខយោងព្រះកេសា ហើយទ្រង់ព្រះជដាបញ្ចកុធ ឡើងគង់លើព្រះរាជរថទឹម អស្សតរ ៦ តាមក្បួនហែរតាមផ្លូវឃ្លាំងប្រេងកាត បត់ទៅឯកើតដល់ស្ថានឥន្ទធនូ ចូលព្រះពន្លាកក់ ១ ។

លោកឡឺរេស៊ីដង់សុប៉េរីយ៉ើរ និងសម្តេចឥសីកម្ពុធិបតីចាំទទួលព្រះករុណា ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យ ថ្វាយព្រះសិទ្ធសេក្រស់ស័ង្ខយោងព្រះកេសា រួចទ្រង់ព្រះមហាមាលាឡើងគង់ព្រះទីនាំងអស្សតរតាមផ្លាធំ មកដល់មុខផ្ទះ ប្រូតិកតូរ៉ាត់ ស្តេចចូលប្រថាប់មានក្រុមយុទ្ធនាថ្វាយគំនាប់ ។

មានលោកគូវែរណើរយេណេរ៉ាល់ និងលោកឡឺរេស៊ីដង់សុប៉េរីយ៉ើរទទួលថ្វាយសាធុការពរ ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យ ថ្វាយព្រះឧទកក្រស់ស័ង្ខយោងព្រះកេសា រួចស្តេចទ្រង់ព្រះមហាមាលា ទ្រង់ព្រះពាតឡើងគង់លើព្រះទីនាំងគជេន្ទ្រ ព្រះរាជដំណើរតាមក្បួនហែចូលក្នុងព្រះបរមរាជវាំង ដល់កើយខាងមុខព្រះទីនាំងសម្រាន្តភិរម្យ ទ្រង់យាងតាមព្រះទីនាំងសម្រាន្តភិរម្យ សក្ខណាកាំភ្លើង ២១ ដង ។

លោក ឡឺរេសីដង់ សុប៉េរីយ៉ើរ និងសម្តេចព្រះឥសីកម្ពុធិបតីទទួលហែព្រះករុណាទៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យថ្វាយព្រះសិទ្ធសេក្រស់ស័ង្ខ រួចហែស្តេចយាងតាមក្បួនហែចូលទៅប្រថាប់ក្នុងព្រះទីនាំងព្រះមហាមន្ទីរ ។

ល្បែងមហាស្រពលេង និង ល្ខោនរាំដល់ម៉ោង ១៨ គឺម៉ោង ៦ រសៀលលើក អុជពន្លឺប្រទីបតាំងតុដល់អធ្រាត្រ ។

ម៉ោង ២០ គឺម៉ោង ៨ យប់ លោកឡឺគូវែរណើរ យេណេរ៉ាល និង លោកឡឺរេស៊ីដង្ត សុប៉េរីយ៉ើរ រៀបរៀងថ្វាយគោជន៍ព្រះករុណាទ្រង់ ស្ទាយឯប្រូតិកតូក៉ត់ ។

ម៉ោង ២២ គឺម៉ោង ១០ យប់ ទទួលលៀងអស់អ្នករាជការបារាំងសែស រាជការខ្មែរ និង មហាជនទាំងអស់កំសាន្តសប្បាយក្នុងមន្ទីរប្រូតិក-តូក៉ត ។

## គម្រប់ ៦ ថ្ងៃ ធ ៨ កើត ខែទុតិយាសាធ គឺថ្ងៃទី ២៥ ខែសូយេត

ម៉ោង ៦ ព្រឹក សាតុដែលតាំងគ្រឿងសក្ការបូជា ។

ម៉ោង ១៧ គឺម៉ោង ៥ រសៀល ព្រះករុណាទ្រង់គ្រឿងជម្នតា ស្ដេចចេញលត់ទៀនជ័យ និងប្រគេនទេយ្យធម្មព្រះសង្ឃក្នុងព្រះទីនាំងទេវា-វិនិច្ឆ័យ ។

## ក្បួនវិធីឡើងព្រះទីនាំងមហាមន្ទីរក្នុងព្រះបរមរាជវាំង

ដល់ពេលហោត្រូវបាល័ដ្ឋទូលឆ្ងង់ក្រុមវាំង ក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ឧកញ៉ាវាំងវរវៀងជ័យ ត្រូវរៀបក្បួនហែព្រះករុណាស្ដេចព្រះរាជដំណើរឡើងព្រះទីនាំងមហាមន្ទីរតាមលើមាគ៌ាក្រាលកន្ទេលនិងសំពត់សលើ ។

ឧកញ៉ាវង្សាសារពេជ្រ ចាងហ្វាង ឧកញ៉ាសុត្តន្តប្រីជា ចាងហ្វាងក្រុមព្រះរាជបណ្ឌិត ត្រូវនិមន្តព្រះពុទ្ធរូប តម្កល់លើតោក បាំងព្រះក្លស់ពណ៌ស ហែមុខព្រះករុណា ។

សម្ដេចព្រះឥសីភទ្ធធិបតី ព្រះព្រហ្មាធិរាជ ឧកញ៉ាហោរាធិបតីចាន់ ហ្វានហែក្រោយព្រះពុទ្ធរូប ឧកញ៉ាកោសាធិបតីទិន ឧកញ៉ាព្រះឃ្លាំង ធិបតីនាយឃ្លាំងមណីរត្ន អញ្ជើញក្អមដី ១ គូ តម្កល់លើតោក ឧកញ៉ាបវរ នាយកអញ្ជើញក្លុយ ១ គូ តម្កល់លើពានមាស របស់ទាំងនេះ ជាគ្រឿង គ្រជាក់គ្រជុំ ចម្រើនព្រះសិរីសួស្ដីសុវត្ថិពិភទ្ធមង្គលជ័យ ។

## ហែក្រោយព្រះករុណា

១- ស្ដ្រីកែវ ១ នាក់ស្លៀកសំពត់សារបាប់ស ឬ ល្បើកសសំឡប ពានាគតសប៉ានឃ្មឹប អញ្ជើញព្រះទម្រង់អស្សឡើយ ។

## ស្ដ្រីមង្គលទាំង ៤ ទ្វីបគឺ

២- ស្ដ្រីបូព៌ាវិទីទ្វីប ១ ស្លៀកសំពត់សារបាប់ ឬ ល្បើកពណ៌ពានាពណ៌ លឿងកាច់ផ្កាមាស ។

៣- ស្ដ្រីជំពូទ្វីប ១ ស្លៀកសំពត់សារបាប់ ឬ ល្បើកពណ៌ ពានាពណ៌ ពេជ្រ កាន់ផ្កាមាស ។

៤- ស្ដ្រីអបរគោយានទ្វីប ១ ស្លៀកសំពត់សារបាប់ ឬ ល្បើកពណ៌ ពានាពណ៌លឿងខ្ចីកាន់ផ្កាប្រាក់ ។

៥- ស្ដ្រីឧត្តរកុរុទ្វីប ១ ស្លៀកសំពត់សារបាប់ពណ៌ ឬ ល្បើក ពានា ពណ៌មរកត កាន់ផ្កាប្រាក់ ។

ស្ត្រីទាំង ៥ នេះ ត្រូវរើសក្នុងពូជត្រកូលប្រកបដោយលក្ខណបរិសុទ្ធ រូបរៀងល្អ ។

៦- ស្ត្រី ១ នាក់ស្លៀកសារបាប់ ឬ ល្បើកសំឡុយ ពានាតាតប៉ាន ឃ្មឹបអញ្ជើញព្រះពានមាស តម្កល់ថវិកាសារបាប់ដាក់ត្បូងផ្សេង ៗ ។

៧- ស្ត្រី ១ នាក់ ស្លៀកសារបាប់ឬល្បើក សំឡុយពានា តាតប៉ាន ឃ្មឹប អញ្ជើញព្រះពានតម្កល់ថវិកាសារបាប់ដាក់សុវណ្ណ ( មាស ) ។

៨- ស្ត្រី ១ នាក់ស្លៀកសារបាប់សំឡុយ ពានាតាតប៉ានឃ្មឹបអញ្ជើញ ព្រះពានតម្កល់ថវិកា សារបាប់ដាក់រជត ( ប្រាក់ ) ។

៩- ស្ត្រី ១ នាក់ស្លៀកសារបាប់សំឡុយ ពានាតាតប៉ានឃ្មឹបអញ្ជើញ ព្រះពានតម្កល់ មណីសិលា បិទមាសជារបស់មង្គល ។

១០- ស្ត្រី ១ នាក់ ស្លៀកសារបាប់ ឬ ល្បើកសំឡុយ ពានាតាត ប៉ានឃ្មឹប អញ្ជើញព្រះពានតម្កល់ ត្រឡាចបិទមាស ។

១១- ស្ត្រី ១ នាក់ ស្លៀកសារបាប់ ឬ ល្បើកសំឡុយ ពានាតាតប៉ាន ឃ្មឹប អញ្ជើញព្រះពានតម្កល់ ថវិកាដាក់លាក់បិទមាសទុកជាលក្ខិណា ព្រះទីនាំង ។

១២- ស្ត្រី ១ នាក់ ស្លៀកសំពត់សារបាប់ ឬ ល្បើកពានាតាមពណ៌ បី នាងវិឡារធ្មាញី ពាក់ដីដាំត្បូងពេជ្រ ត្បូងទទឹម ត្បូងមរកត តំណាងកសិរក្សាព្រះទីនាំង ។

១៣- ស្ត្រី ១២ នាក់ ស្លៀកសំពត់សារបាប់ ឬ ល្បើកពានាតាតពណ៌

អញ្ជើញគ្រឿងសម្រាប់ឥស្សរិយយសព្រះមហាក្សត្រ ។

ព្រះរាជវង្សានុវង្ស ស្ត្រីទីព្រះស្នំក្រុមការខ្ញុំរាជការ ស្ត្រីជំទាវខុនណាង គ្រប់ក្រុមហែតាម ។

ឯឧកញ៉ាមហាមន្ត្រី ឧកញ៉ាមហាទេព ស្លៀកសំពត់ ពាក់អាវសារ ចាប់ទឹកអាវផាយ ពាក់លំផក ។

ព្រះឥន្ទ្រកោរព្ភការ ព្រះព្រហ្មធិរាជ ស្លៀកស ពាក់អាវផាយតាំង ៤ នាក់ តំណាងទេវតា ឈរប្រចាំសោបាណព្រះទីនាំងមហាមន្ទីរមានគ្រឿង បំអាប ១ គូ បង្អួម ១ គូ និង ក្បាលជ្រូក ១ គូ សែនយក្ខទេវតា ដែលរក្សាព្រះសោបាណ ។ លុះក្បួនហែមកដល់ព្រះសោបាណនោះ សម្តេចព្រះឥសីកន្ធធិបតី និង ឧកញ៉ាហោរាធិបតីចាងហ្វាងសូត្រប្រកាសទេវតាថា ៖

៚ កោត្ថោ ទេវសំឃាយោ

( ប្រែថា ) បពិត្រអស់ពពួកទេវតាដ៏ចម្រើន បានមកសន្និបាតប្រជុំព្រមនៅស្ថានទីនេះហើយ ឬទៅណា (ទើបតំណាងទេវតាទាំង៤ ឆ្លើយថា៖ យើងសណ្ឋិតនៅរក្សាមហាស្វេតច្ឆត្រ នៅស្ថានវិមានព្រះមហារាជមន្ទីរ ក្នុងព្រះបរមរាជវាំងនេះជានិច្ច មិនបានទៅណាទេ អ្នកមានការអ្វីសូមថ្លែងសេចក្តីមក ) ។

ទើបសម្តេចឥសីកន្ធធិបតី និង ឧកញ៉ាហោរាធិបតី ចាងហ្វាងឆ្លើយថា យើងខ្ញុំហែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះនាមព្រះបាទសម្តេចព្រះ

ស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្សហរិរាជបរមិន្ទ្រ ភូវ៉ៃណារ៉ៃក្រៃកែវហ្វាសុឡាឡៃ ព្រះចៅក្រុងកម្ពុជាធិបតី ស្តេចព្រះរាជដំណើរ មានគ្រឿងឥស្សរិយយស គ្រប់តាមទំនៀម មកឡើងព្រះទីនាំងមហាមន្ទីរ ជាទីគង់លើព្រះទែនក្រោម ព្រះមហាស្វេតច្ឆត្រ ទ្រង់គ្រងរាជសម្បត្តិ ជាអម្ចាស់ជីវិតលើត្បូង សូមទេវតាចម្រើនព្រះជន្ម ឲ្យបាន ១០០ ព្រះវស្សា ជាសុខក្សេមក្សាន្តស្ថិតស្ថេរចិរកាលតទៅ បើទេវតាយល់ថា វេលានេះជាមហាវិជ័យមង្គលឫក្សមានជោគល្អ ចូរសម្តែងមក ៗ ( ទេវតាឆ្លើយថា ) យើងស្ថិតនៅរក្សាព្រះមហារាជមន្ទីរនេះ និងព្រះមហាស្វេតឆ័ត្រ ក្នុងព្រះបរមរាជវាំងនេះបម្រុងថ្វាយព្រះបាទសម្តេច ព្រះស៊ីវត្ថិមុនីវង្ស ចមចក្រពង្ស ព្រះចៅក្រុងកម្ពុជាធិបតី ស្រេចហើយវេលានេះ ជាជ័យមង្គលឫក្សជោគល្អ ហើយយើងជាទេវតា សូមថ្វាយព្រះមហាស្វេតច្ឆត្រត្តមហាមន្ទីរស្ថាន សូមអញ្ជើញព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងឡើងគង់លើព្រះមហាមន្ទីរស្ថាន សូមចម្រើនសេចក្តីសុខសួស្តីវិជ័យមង្គល មហាប្រសើរថ្វាយព្រះជន្មទីឃាយុ យឺនយូរ បាន ១០០ ព្រះវស្សា ទ្រង់រាជសម្បត្តិរក្សាព្រះពុទ្ធសាសនា ព្រាប់ទំនៀមព្រះនគរ ព្រះរាជវង្សានុវង្ស ព្រះសង្ឃក្រុមការ អគ្គមហាសេនាសេនាបតី នាម៉ឺនសព្វមុខមន្ត្រី ករិបណ្ឌិត ព្រាហ្មណ៍ព្រឹទ្ធាមាត្យ ជំទាវខុនណាង និងខ្ញុំរាជការ អាណាប្រជានុរាស្ត្រ ឲ្យប្រកបដោយនូវសិរីសុខមហាប្រសើរ ស្ថិតស្ថេរចិរកាលតទៅហោង ៗ

ស្តេចព្រះឥសីភទ្ទធិបតី និង ឧកញ៉ាហោរាធិបតី ទទួលសាធុការពារ ក្រាបបង្គំទូលអញ្ជើញស្តេចយាងឡើងតាមព្រះសោបាណ ទូងគងជ័យ ព្រាហ្មណ៍ផ្លុំស័ង្ខត្រែតន្ត្រី ។ ទើបឧកញ៉ា វាំងវរវៀងជ័យ ចេញមកទទួល ក្រាបថ្វាយបង្គំ អញ្ជើញព្រះករុណាស្តេចយាងចូលទៅក្នុងព្រះមហាមន្ទីរ ក្រឡាព្រះបន្ទំ ទ្រង់យាងទតគ្រប់ទី តាមសព្វព្រះរាជហឫទ័យ រួចជួបជុំព្រះរាជវង្សានុវង្ស ព្រះស្នំក្រមការ ព្រះគ្រូ អគ្គមហាសេនាសេនាបតី នាម៉ឺនសព្វមុខមន្ត្រីក្រាបថ្វាយបង្គំគាល់ ។

រួចព្រះករុណា ស្តេចយាងទៅថ្វាយបង្គំ ព្រះបរមអដ្ឋិក្នុងហោព្រះអដ្ឋិ ហើយស្តេចយាងចេញ ទ្រង់ព្រះសណ្តាប់ សូត្រមន្តក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ក្នុងព្រះរាជពិធីឡើង ព្រះមហារាជមន្ទីរ និងរាជាភិសេក ។

## ក្បួនរំលឹកព្រះមហាក្រស័ត្រដែលទ្រង់ព្រះរាជាភិសេក

សោមហាសត្តោ សិនេរុអធិដ្ឋានកាយំ បញ្ញាកិ
សេតំ អធិដ្ឋាសិ ។

ឯព្រះមហាក្សត្រ លុះបានរាជាភិសេក ជាឯករាជហើយគប្បីអធិដ្ឋានព្រះអង្គថា ព្រះអង្គយើងនេះគឺភ្នំព្រះសុមេរុរាជ ដ៏តាំងនៅចារិកព្រះធរណីក្នុងប្រថពីតល ឯព្រះនេត្ររបស់យើងខាងស្តាំគឺព្រះអាទិត្យ ព្រះនេត្រយើងខាងឆ្វេងគឺព្រះចន្ទ្រ ដ៏ចុះបំភ្លឺលោកឲ្យភ្លឺរុងរឿង ច្បាស់ស្រឡះនៅក្នុងព្រះហឫទ័យ និង កាត់នូវទុក្ខភ័យនៃមនុស្សឲ្យប្រាកដ ក្នុងព្រះឧបេក្ខាបរិញ្ញត្តិ

ដែលក្តៅក៏ឲ្យក្តៅ ដែលត្រជាក់ក៏ឲ្យត្រជាក់ តាមព្រះបវេណី ដូចគ្នា ព្រះហស្ត ទ្វេនិ ស្មា ទូរព្រះបាទ ទាំងពីរនោះ គឺទ្វីបទាំង ៤ ស្វេតច្ឆត្រទាំង ៦ ជាន់នោះគឺ ឆកាមាវចរទាំង ៦ អធិដ្ឋានព្រះខន្ធវង្វាប់មិនបានញាប់ញ័រ ក្នុងព្រះរាជហឫទ័យ ព្រះមហាមកុដនោះសោត គឺកំពូលវិមានព្រះឥន្ទ្រ ព្រះទ័ននោះគឺប្រាង្គប្រាសាទនិងគាត់មន្ទិលនៃមនុស្សឲ្យឃើញច្បាស់ សព្វលោកធាតុ ។

ឯគ្រឿងប្រដាប់គឺព្រះក្លសារក្តកម្ពុលនោះ គឺក្នុងក្នុងមាទដំណាប់ក្នុងព្រះសុមេរុរាជ ។ ឯព្រះមនុម្មមហាក្សត្រនោះគឺព្រះវិន័យធម៌ដឹកម្រង់រាស្ត្រប្រដៅឲ្យប្រាកដក្នុងរៀងក្នុងកំណត់ជម្ពូទ្វីប សុពណ៌បាទនោះគឺផែនដីជាវិរងក្នុងព្រះសុមេរុរាជ និងជាទីអាស្រ័យនៃអាណាប្រជានុរាស្ត្រទាំងឡាយ សព្វដែនឲបទ័ព្ទ ... ដោយព្រះយសព្រះតេជរបស់ព្រះមហាក្សត្រនោះផង ។

ឆសរបញ្ញត្តិយា មហាសត្តអប្បកាយោ បញ្ញត្តិយោ
អបរ្យមាតិ ។

មានគុណគម្ពីរព្រះបាលី ព្រះលោកបញ្ញត្តិសម្រាប់ព្រះបរមក្សត្រ និងកេព្រព្រះ...ឲ្យរៀន គឺកុំឲ្យឈ្មៀងព្រះនេត្រទត មើលព្រះអាទិត្យ ១ កុំឲ្យខ្ពុំកាលណែព្រះអាទិត្យរះឡើង ១ កុំឲ្យសោយព្រះសិទ្ធិសេល្អក ព្រះសិទ្ធសេព្រាំ, ... ព្រះស្រលក ១, កុំឲ្យសោយត្រីសាច់ដំណាប និង

ខ្លាញ់ ១, កុំឲ្យសោយព្រះឱសថដែលពេទ្យផ្សំមិនគួរ នឹងសោយ ១, កុំឲ្យសោយរបស់ដែលទំពារ ដែលខាំ ១, កុំឲ្យសេពកាមគុណ នឹង ស្ត្រីមានអាយុ ៤០ ឆ្នាំ និង ៥០ ឆ្នាំ ១, កុំឲ្យទ្រង់ព្រះភូសាមានសាច់ជ្រោកគគ្រោកគគ្រាតមិនល្អ ១, ហេតុទាំងដប់ប្រការនេះ មិនគួរដល់ព្រះបរមក្សត្រឡើយ ។

## គ្រឿងទេយ្យទាន

ដែលត្រូវប្រគេនព្រះសង្ឃក្នុងឱកាសបុណ្យរាជាភិសេក ។

ព្រះសង្ឃបម្រើនព្រះពុទ្ធមន្ត ឡើងព្រះទីនាំងមហាមន្ទីរនិងបុណ្យរាជាភិសេក រួមទាំងអស់ ៦៧ អង្គ ។

ត្រូវត្រៀមរាំងអាលក្ខណ៍ និង យាំងទិញគ្រឿងទេយ្យទានដូចមានចំនួនខាងក្រោមនេះក្នុងមួយមុខ ៗ ។

ត្រៃព្រម្នាង, ទេសន្នាង, ស្បង់ព្រៃ, ស្បែកជើងដង្កៀប, កន្សែងស, គោមឡុតទៀនបាកាំង, ហោទៀនបាកាំងធំវែង កាំបិតកោ, ថ្នូសំលៀកកាំបិតកាស្រោកតែណាយីស៊ីម, កំសៀវស្ពាន់, ស្ករបាកាំង, ធូបក្រអូបយ៉ាងល្អឈើគូសភ្លើង, ឆ័ត្រដងឫស្សី ។

រៀបគោជនាហារចង្ហាន់តន្លាយព្រះ ៣ សម្រាប់ ចង្ហាន់ព្រះសង្ឃ ៤៨ សម្រាប់ ។ មុខងារដាំបាយចង្ហាន់ ៤៨ អង្គ ត្រូវ ៧២ នាឡិ ទិញឧសដុត ។

ឧកញ៉ាបម្រុងសក្ការ និង ព្រះប៉ាន់ធិបតី មុខងារខាងដាំតែរៀបដាំតែប្រគេនព្រះសង្ឃ ៗ តែណាយីស៊ីម ៤ សំណុំ ស្ករសបាំង ១០ នាឡិ ធូបកោងកាង ៤០ នាឡិ ៗ

ក្រុមរាជការ ស្ត្រីខាងក្នុងព្រះបរមរាជវាំង ត្រូវរៀបប្រគល់ឲ្យមុខងារប្រគេន និងប្រើការក្នុងបុណ្យ គឺក្រមួនឃ្មុំ ៦០ នាឡិ អម្បោះប្រឆេះ ៤ នាឡិ, ធូបលឿង ៣០ សំណុំ, ទៀនបាំងស្រាត ៩ ហិប, ទៀនបាំងស្រោប ៣ ហិប ថ្នាំ ៣០ នាឡិ, ស្លាស្ងួន៣០ នាឡិ, ម្លូសម្រាំង ៥ ពាន់, ស្លាផ្កា ៨ នាឡិ, ស្លឹកបេកស្រស់ ២៥០ សំណុំ, ស្លឹកបេកក្រៀម ១២០ សំណុំ, កំបោរក្រហម ២ ដុំ, ធូបកោងកាង១ ហាប, ប្រេងដូង ១នាឡិ ៗ

# ក្បួនហែ

## ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង
## ប្រទក្សិណព្រះនគរ គឺជុំវិញក្រុងភ្នំពេញជាក្បួនមឿង
## ក្រុងកម្ពុជាធិបតី
## ក្នុងឱកាសព្រះរាជពិធីរាជាភិសេក

រៀបជា ៨ ជួរ

ទង់ជ័យរូបអាជានេយ្យធំមាស ១

ភ្លេងបាកំង ១ វង់

ទង់ប្រាសាទធំ ១

ទង់ប្រាសាទធំ ១

ភ្លេងបាកំង ១ វង់

យុទ្ធនាបាកំងសែស ១ ក្រុម

នាយត្រួត ១ នាក់

ខ្លួនយ៉ាវ ១ វង់

នាយត្រួត ១ នាក់

យុទ្ធនាធិការបាកំងសែស ១ ក្រុម

ក្រុមពិជ័យសង្គ្រាមខ្មែរ ១ ក្រុម

នាយត្រួត ១ នាក់

ភ្លេងពិផាត ១ វង់

នាយត្រួត ១ នាក់

ក្រុមពិជ័យសង្គ្រាមខ្មែរ ១ វង់

ទាហានកាំភ្លើងធំ

នាយត្រួត

ភ្លេងពិផាត ១ វង់ធំ

នាយត្រួត

ទាហានកាំភ្លើងធំ

ក្រុមកញ្ញាស្រុក ១ វង់

នាយត្រួត

ខ្លួនវៃក ១ វង់

នាយត្រួត

| | |
|---|---|
| ក្រុមក្បាស្រុក ១ វង់ | កាព់ឡឺរ ជិះសេះ ៤៥ |
| ទង់នាគ ៣០ | ដាវខែល ៥០ |
| សាព់តត្រួត | មន្ត្រីយួន |
| ខ្វង់ខែក ១ វង់ | ក្មេងម៉ាឡាយូ ១ វង់ |
| សាពតត្រួត | មន្ត្រីយួន |
| ទង់នាគ ៣០ | ដាវខែល ៥០ |
| ក្រុមក្បាព្រះអគ្គ ១ ក្រុម | ឧកញ៉ាទេវដូនជិះសេះ |
| នាយត្រួត | កន្ទុយក្ងោក |
| ក្មេងជ្វា ១ វង់ | មន្ត្រីចិន |
| នាយត្រួត | មន្ត្រីចិន |
| ក្រុមក្បាព្រះអគ្គ ១ ក្រុម | ឧកញ៉ាពជវពន្ទុកូលជិះសេះ |
| នាយត្រួត | កន្ទុយក្ងោក |
| ក្មេងចិន ១ វង់ | យោក្បត្រ |
| នាយត្រួត | យោក្បត្រ |
| ទង់ក្អុប ៣០ | តម្រួតរំពាត់បាច់ ៣០ |
| សាព់តត្រួត | សុកា |
| សាព់តត្រួត | ស្គរជ័យ |
| ទង់ក្អុប ៣០ | តម្រួតរំពាត់បាច់ ៣០ |
| កាព់ឡឺរ ជិះសេះ ២៥ | បាឡាក់ |
| មន្ត្រីបាម ជ្វា ១០ | បាឡាក់ |

ទន់ម្ករ

ចៅហ្វាយស្រុក ចៅហ្វាយខេត្រ

គនជ័យ

ចៅហ្វាយស្រុក ចៅហ្វាយខេត្រ

ទន់ម្ករ

មន្ត្រីសក្ត ៦ ហូពាន់ដល់ ៨ ហូពាន់

ដើរហែ

មន្ត្រីសក្តិ ៦ ហូពាន់ដល់ ៨ ហូពាន់

ដើរហែ

តម្រួតមុខកាន់លំពែង ២០

តម្រួតមុខកាន់លំពែង ២០

ចាមរ ៥

ខ្វង់ផ្ចាក់ក្រហម ១០

ខ្វង់ផ្ចាក់ប្រាក់ ១០

ខ្វង់ផ្ចាក់មាស ១០

ចាមរ ៥

ព្រាហ្មណ៍ត្រីពឹងពាំង ១០

ព្រាហ្មណ៍ត្រីពឹងពាំង ១០

ព្រាហ្មណ៍ផ្តុំស័ន្ធ ៤

ក្មេងមហោធិក

ព្រាហ្មណ៍ផ្តុំស័ន្ធ ៤

គ្រែ-ង

គ្រែ-ង

ហោក ១

ហោក ១

កូវតាន ៥

ស្តេចមាយ ១០

ស្តេចមាយ ១០

កូវតាន ៥

ព្រះវង្ស ១០

ព្រះវង្ស ១០

មន្ត្រីកងសក្តិ ៩ ហូពាន់ជិះសេះ

មន្ត្រីកងសក្តិ ៩ ហូពាន់ជិះសេះ

អភិរម្យ ៤

ឧកញ៉ាមហាមន្ត្រីជិះសេះ

ឧកញ៉ាអគ្គមហាសេនាធិបតី ជិះ

គ្រែយានមុខ

ឧកញ៉ាមហាទេពជិះសេះ

ឧកញ៉ាពិងរវៀងជ័យ ជិះគ្រែ
យៀង
ចាំងសែង
ព្រះរាជយានុមាត្យ ព្រះករុណាគង់
ចាំងសែង
អាលក្ខណ៍អញ្ជើញ ព្រះផ្កាមាស
ផ្កាប្រាក់
ថ្វាយបួយទាន
ឧកញ៉ាចក្រីធិបតីកុញ្ជរ ជិះគ្រែ
យៀង
ឧកញ៉ាក្រឡាហោមជិះគ្រែយៀង
ព្រះវិជ្ជនីជ័យ
ចាំងសែង
ព្រះវិជ្ជនីជ័យ
ឧកញ៉ាយមរាជជិះគ្រែយៀង
កូសាមាលាអញ្ជើញគ្រឿង
កូសាខាលាអញ្ជើញគ្រឿង
ទង់សត្វឥន្ទ្រី ៣០

ព្រះអគ្គម្ចាស់ជិះសាលៀង
ជិះសេះហែ
នាម៉ឺនសក្តិ១០ហូពាន់ជិះគ្រែហែ
មហាតលិកអញ្ជើញគ្រឿង
នាម៉ឺនសក្តិ ១០ ហូពាន់ជិះគ្រែ ហែរ
ព្រះអគ្គម្ចាស់ជិះសាលៀង ជិះសេះ
ហែ
ទង់សត្វឥន្ទ្រី ៣០
គជេន្ទ្រចំឡងសឹក ២
តម្រួតក្រោយកាន់លំពែង ១៥
មហាតលិកប្រសែងជួង
តម្រួតក្រោយកាន់លំពែង ១៥
គជេន្ទ្រចម្បងសឹក ២
គជេន្ទ្រយោង ៤
ព្រះទីនាំងគជេន្ទ្រទ្រង់ករ
ទជេន្ទ្រយោង ..
កាន់ដំបងរម្លួល ៨០ នាក់
សាក៉ត្រែត ១

គជេន្ទព្រះទីនាំងព្រះ

សារ៉ាតត្រួត ៗ

កាន់តំបន់រមួល ៥០ នាក់

ដំរីសេរ ១

គជេន្ទព្រះទីនាំងគជាញជ័យ

មន្ត្រីក្រុមពាំង

មន្ត្រីក្រុមពាំង

ព្រះទីនាំងគជេន្ទគង់

ព្រះទីនាំងគជេន្ទគង់

មន្ត្រីក្រុមពាំង

ព្រះទីនាំងអស្សតរគង់

មន្ត្រីក្រុមពាំង

ព្រះទីនាំងអស្សតររង

ព្រះនរិន្ទសេរីយជិះសេះកន្ទុយ

ក្បាក

ព្រះមហាកដរថទីមសេះ ៦

ព្រះស្រីសាទេពជិះសេះកន្ទុយ

ក្បាក

## ដូចមានផែនទី

## បូករួមក្នុងក្បួនហែ

១ អគ្គមហាសេនា ១

២- សេនាបតី ៤

ព្រះកដវង្សានុវង្សក្សត្រា

៣- គឺ ព្រះអគ្គម្ចាស់ ៥
អ្នកអគ្គម្ចាស់ ២៩ } ៣៤

៤- មន្ត្រីសក្តិ ១០ ហូពាន់ ក្នុង
ក្រុង ១

៥- ចាងហ្វាងក្រុមបារគូបុរោហិត ១

៦- ក្រុមបារគូបុរោហិត ២៦

៧ ចាងហ្វាងក្រុមព្រះវង្ស ១

៨- មន្ត្រីក្នុងក្រុង ៥០០

តុលាការក្នុងក្រុង

| | | |
|---|---|---|
| ៩. ចាងហ្វាង | ៥ | ៧០ |
| ១០. ចៅក្រម | ១៨ | |
| ១១. ក្រឡាបញ្ជី | ២០ | |
| ១២. សមុហបញ្ជី | ២៧ | |
| ១៣. ត្រួតខែត្រ | ១ | ១៦ |
| ១៤. ចៅហ្វាយ | ១៥ | |
| ១៥. ចៅហ្វាយស្រុក | ១២ | ៩៧ |
| ១៦. ចៅហ្វាយខ័ណ្ឌ | ៨៥ | |

## តុលាការខែត្រ

| | | |
|---|---|---|
| ១៧. ចាងហ្វាង | ១៤ | ៩០ |
| ១៨. ចៅក្រម | ២០ | |
| ១៩. ក្រឡាបញ្ជី | ១៣ | |
| ២០. សមុហបញ្ជី | ៤៣ | |

២១. សេនាទាហាន ៦ ក្រុម

២២. នាយត្រួត ៣

២៣. កាក់ឡឺរជិះសេះ ៥០

២៤. គម្រួតមុខកាន់លំពែង ៤០

២៥. គម្រួតមុខកាន់រំពាត់ប្រាប់ ៦០

២៦. មន្ត្រីតាមជ្វា ១០

២៧. ព្រាហ្មណ៍គ្រីពីងពាំង ២០

២៨. -ដ- ផ្លុំស័ង្ខ ៨

២៩. ហោរា ២

៣០. ស្តេចមាឃ ២០

៣១. ព្រះវង្ស ២០

៣២. គម្រួតក្រោយកាន់លំពែង ៣០

៣៣. គម្រួតក្រោយដំបងរបួល ១០០

៣៤. ដាវ ៥០ ខែល ៥០ ជា ១០០

៣៥. ចាំមរ ១០

៣៦. កូវ គាន ១០

៣៧. អគ្គិរម្យ ៤

៣៨. ទង់ ១៨៣

៣៩. ក្លួង ៦ វង្ស

៤០. ខ្ទង់ ឆ្នាក់ ៣០

៤១. គជេន្ទ្របំឡុងសឹក ៤

៤២. គជេន្ទ្រយាង ៨

៤៣. ព្រះទីនាំងគជេន្ទ្រទ្រង់ករ ១

៤៤- គជ្ជេន្ទ ព្រះទីនាំងព្រះ ១
៤៥- ដំរីស ១
៤៦- គជ្ជេន្ទព្រះទីនាំងគជាញជ័យ១
៤៧- ព្រះទីនាំងគជ្ជេន្ទគង់ ១
៤៨- -ដ- រង ១
៤៩ ព្រះមហាកដវថ ១ ទំមសេះ ៦
៥០- ព្រះទីនាំងអស្សតរគង់ ១ ។

៥១- -ដ- រង ១ ។
៥២- មន្ត្រីជិះសេះកន្ទុយក្រោក ៤
៥៣- មន្ត្រីជិះសេះ ៤
បូកផ្តាច់មនុស្ស ១៤៧៧ នាក់
— ដំរី ១៨
— សេះ ៦៦

## ទ្រង់ព្រះរាជានុញ្ញាត

ព្រះករុណាព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្សព្រះ
ចៅក្រុងកម្ពុជាធិបតី ។

ជាអម្ចាស់ជីវិតលើត្បូង

ឡាយព្រះហស្ថលេខា : ព្រះស៊ីសុវត្ថិ-មុនីវង្ស

យល់ព្រម

ក្រុមព្រះសេនាបតី

ក្រុមព្រះនរោត្តម ភាណុវង្ស ទីអគ្គមហាសេនាធិបតី

ភាណុវង្ស

ឧកញ៉ា ចក្រីធិបតីកុញ្ជារ

**ប៉ុន**

ឧកញ៉ាយោមរាជ

**ជា**

ឧកញ៉ាវាំងវរវៀងជ័យ

**ជួន**

ក្រុមហ្លួងស៊ីសុវត្ថិ សុផានុវង្ស

ទីក្រឡាហោម

**សុផានុវង្ស**

# អំពីតាំងតុរបស់ព្រះរាជបណ្ណាល័យកម្ពុជា

ក្នុងឱកាសបុណ្យរាជាភិសេក

## អ្នកស្រី ស៊ុយ សាន ការប៉ុឡែស អធិប្បាយ

---

ក្នុងឱកាសពិធីបុណ្យ រាជាភិសេក ព្រះករុណាព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ-មុនីវង្ស ព្រះរាជបណ្ណាល័យកម្ពុជា បានចាត់ការរៀបចំ តាំងតុថ្វាយជាទីសមនឹងព្រះកិត្តិយស ដ៏ខ្ពង់ខ្ពស់ថ្លៃថ្លាណាស់ គឺបានរចនាជាម្កុដ ដ៏ពាសទីទៅនូវសំពត់ពណ៌លឿងទុំ មានកម្ពស់ជាង ៣ ម៉ែត្រ កំពូលនៃម្កុដនោះ បានរចនាជាស្នា ចាំងឆ្លុះជារង្វង់មូល ឯតែម្កុដទាំងសងខាងបានប្រដាប់ដោយកែវ ប្រផេះអគ្គិសនីជាច្រើនមានពណ៌ក្រហម និងបៃតងរៀបរៀង ឆ្លុះពណ៌គ្នាជាជួរជុំវិញ ខាងក្នុងនៃម្កុដនោះ បានរៀបសុទ្ធតែសៀវភៅ មានពណ៌មាសបញ្ឈររៀងគ្នាទាំងសងខាងម្កុដនោះ មានរៀបតុចូល ១ ម្ខាងហើយបានតម្រៀបតម្រួតសៀវភៅផ្សេងៗ ដែលទើបនឹងបោះពុម្ពហើយ ក្នុងជាន់ក្រោយ ធ្វើជាក្នំ គឺសៀវភៅដែលអធិប្បាយអំពីប្រាសាទខ្លះនៅអង្គរ ១ ទសបារមីកថា ១ និង គតិលោក ខ្សែពីរ ១ ។

ក្នុងពេលរាត្រី ដោយអំណាចពន្លឺក្រហមនិងពន្លឺបៃតង ឆ្លុះឆ្លាស់គ្នា ម្កុដនោះហាក់ដូចជាអណ្ដែតត្រសែត នភាល័យប្រទេស មានសណ្ឋាន

ដូចជាមាសក្រហមរន្ទាលប្រាលឆ្អៅ ជាទីគួរគេយគន់ ហើយសក្តិសម ដល់ព្រះរាជពិធីរាជាភិសេក នៃព្រះករុណាព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស ព្រះចៅក្រុងកម្ពុជាធិបតី ៗ

# ព្រះបាទសម្តេចព្រះស៊ីសុវាងវង្ស

### ព្រះចៅក្រុងលាវ

## ស្តេចចូលក្រសាលក្នុងព្រះរាជបណ្ណាល័យកម្ពុជា

នៅវេលាដែលស្រេចបុណ្យរាជាភិសេកជាជ្រះស្រឡះហើយ ព្រះបាទសម្តេចព្រះ ស៊ីសុវាងវង្ស ព្រះចៅក្រុងហ្លួងព្រះបាងទ្រង់ឈ្វេងយល់ថា នឹងមិនទ្រង់ព្រះរាជដំណើរចេញពី ក្រុងភ្នំពេញ ដោយឥតបានស្តេចចូលក្រសាលក្នុងព្រះរាជបណ្ណាល័យ មួយអន្លើនឹងព្រះអង្គម្ចាស់ពេជរត្ន និងបណ្ណាអ្នករាជការ ដែលហែហមមកទាំងប៉ុន្មានឡើយ ។

កាលពីថ្ងៃ ២៥ សូរយេត ឆ្នាំ ១៩២៨ អ្នកស្រីស៊ុយសានការប៉ុឡែស ជាបណ្ណារក្សនៃព្រះរាជបណ្ណាល័យ ជួបជុំនឹងអ្នករាជការក្នុងមន្ទីរនេះគ្រប់គ្នា បានអធិប្បាយសេចក្តីយ៉ាងវែង ថ្វាយស្តេចស្រុកលាវ អំពីសេចក្តីចម្រើន និងពទ្ធិរបស់មន្ទីរថ្មីនេះ បានថ្វាយ សៀវភៅគ្រប់យ៉ាងដែល ព្រះរាជបណ្ណាល័យបានផ្សាយ ហើយសៀវភៅទាំងនោះ សុទ្ធតែធ្វើ ក្របពណ៌មាសទាំងអស់ ព្រះចៅក្រុងលាវទ្រង់គាប់ព្រះរាជហឫទ័យពេញទី អំពីដែលបានឃើញអ្វីៗ ទាំងអស់ ហើយទ្រង់ថ្លែងសេចក្តីសរសើរជាច្រើនប្រការដល់បណ្ណារក្សនៃព្រះរាជបណ្ណាល័យ សេចក្តីសរសើរជាការនាំឲ្យព្រះរាជបណ្ណាល័យរឹងរឹតតែមានកម្លាំងក្លាហាននឹងធ្វើការតទៅទៀត ។

ព្រះអង្គម្ចាស់ ពេជរត្ន បានយាងចូលព្រះរាជបណ្ណាល័យក្នុងគ្រាក្រោយម្តងទៀត ហើយបានមានបន្ទូលអំពីដែលព្រះចៅណាត មានសេចក្តីប្រាថ្នាក្នុងព្រះរាជហឫទ័យ ជានឹងតាំងបង្កើតមន្ទីរ ១ ឲ្យមានបែបសណ្ឋានដូចជាព្រះរាជបណ្ណាល័យកម្ពុជានេះ ព្រមទាំងសូមជំនួយពីព្រះរាជបណ្ណា-ល័យនិងសូមផលដែលកើតឡើងដោយសេចក្តីជំនាញប៉ិនប្រសប់ នៃមន្ទីរនេះផង ។

# សេចក្ដីអធិប្បាយព្រះរាជបណ្ណាល័យ

របស់លោកស៊ីលវ៉ាំងឡេវី

## ម៉ាដឹមូអាហ្សែលការប៉ឺឡែស

ប្រែពីភាសាអង់គ្លេសជាភាសាបារាំងសែស

## ក្រុមការ ជុំ-ម៉ៅ ប្រែមកជាភាសាខ្មែរ

---

គឺក្នុងទស្សនាវដ្ដី នៅស្រុកជប៉ុន ព្រះពុទ្ធជាភាសាអង់គ្លេស ជាភាសាដែលអ្នកប្រាជ្ញក្នុងស្រុក អឺរ៉ុប កំពុងតែប្រើក្នុងការព្រះពុទ្ធសាសនាជាងគេ ដែលលោកស៊ីលវ៉ាំងឡេវី ជាគ្រូធំបំផុត ក្នុងការស្រាវជ្រាវរកពុទ្ធសាសនា បានចុះសេចក្ដីដូចមានខាងក្រោមនេះ អំពីព្រះរាជបណ្ណាល័យកម្ពុជា ។

## អំពីព្រះរាជបណ្ណាល័យកម្ពុជា

ប្រទេសឥណ្ឌូស៊ីនបារាំងសែស ជាផ្លូវបែកមុខ ៤ នៃសាលាធំ ២ របស់ព្រះពុទ្ធសាសនាស្រុកខ្មែរនិងស្រុកលាវជាពួកខាងហីនយាន ដែលមានគម្ពីរដីកាជាភាសាបាលី ឯចំណែកស្រុកអណ្ណាមនិងស្រុកតុងកឹង ជាពួកដែលក្លាយពីស្រុកចិនមក គឺពួកមហាយាន ។

ឯនគរបារាំងសែសជាទីកើតនៃវិជ្ជានានា ក្នុងពុទ្ធសាសនាដោយការថ្មីដៃរបស់អ្នកប្រាជ្ញធំៗ ដូចយ៉ាងលោក អាបែលរេមុយសាត់ និង អឺ-សែនប៊ុរនូហ្វ ដែលលោកបានចំស្រាវជ្រាវរកក្នុងពេលនេះ ក្រុងបារាំង

សេស ត្រូវធ្វើឲ្យឃើញកស្តុតាងផលប្រយោជន៍នៃការដែលបានស្រាវជ្រាវឃើញឡើង ។

អនាគតកាលនៃប្រទេសឥណ្ឌូស៊ិន អាស្រ័យយ៉ាងធំដោយតម្លៃសតិបញ្ញា និង ក្រិត្យក្រមអ្នកបួសក្នុងពុទ្ធសាសនា ដោយហេតុថាវត្ត-អារាមជាទីដើម នៃការសូត្ររៀន របស់អ្នកស្រុក ឯសាលាបាលីវិសេសនៅក្នុងបូព៌ាប្រទេស ដែលបានតាំងបង្កើតពីកាលឆ្នាំ ១៩៤៩ ក្នុងអធិបតីដ៏ប្រសើរថ្លៃថ្លានៃលោក ល៊ីហ្វីណូត៍ នោះ ក៏បានទទួលកិច្ចនិងស្រាវជ្រាវរកពង្សាវតារប្រទេសកម្ពុជា និងចំការដែលកប់បាត់ទៅកាលជាន់ដើម មានតាំងបង្កើតសាលា បរិយត្តិ ១ នៅក្រុងភ្នំពេញ ។

នាងស្រីកញ្ញាការប៉ុឡេស ដែលជាអ្នកបានប្រែហើយបានផ្សាយនូវសៀវភៅលោកេស្សរសេត ជាភាសាសំស្ក្រឹតនិងភាសាស្រុកទីបេតបានតាំងជាបណ្ណាគារនៃព្រះរាជបណ្ណាល័យកម្ពុជា រាជមន្ទីរនេះបានផ្សាយនូវទស្សនាវដ្ដីដែលចេញរាល់ខែ ហៅថាទស្សនាវដ្ដី កម្ពុជសុរិយាដែលមាននិយាយសុទ្ធតែខាងការព្រះពុទ្ធសាសនាសេចក្ដីសារប្រវត្តិក្នុងចក្រវាល ។ ដែលយើងបានទទួលតាំងប៉ុន្មាន ធ្វើឲ្យយើងឃើញផលប្រយោជន៍នៃសេចក្ដីតាំងប៉ុន្មានដែលបោះផ្សាយនោះ . . . . .

ព្រះរាជបណ្ណាល័យបានបោះពុម្ពសៀវភៅផ្សាយជាច្រើនមុខណាស់ ។

ស៊ីលវ៉ាំងឡេវី